**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៤.០៦៤/០៨ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៨

# គ.ជ.ប បិទវគ្គបណ្តុះបណ្តាលស្តីពីការឃោសនាបោះឆ្នោត

វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល និងមន្ត្រីនៅទីស្តីការ គ.ជ.ប ស្តីពីការឃោសនាបោះឆ្នោត ដែលបានប្រព្រឹត្តទៅអស់រយៈពេល ២ ថ្ងៃ បានបញ្ចប់នៅរសៀលថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ។

មានមតិសំណេះសំណាលក្នុងពិធីបិទវគ្គនោះ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានថ្លែងថា ការឃោសនាបោះឆ្នោត គឺជាឱកាសមួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ ដើម្បីឃោសនាបញ្ចុះបញ្ចូលអ្នកបោះឆ្នោត ឱ្យគាំទ្របេក្ខជន ឬគណបក្សនយោបាយរបស់ពួកគេ ហើយនៅក្នុងដំណាក់កាលនេះដែរ មន្ត្រីគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ក្រុង និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មានភារកិច្ចជាអ្នកសម្របសម្រួល ដូចនេះត្រូវទាមទារឱ្យពួកគាត់មានសមត្ថភាពក្នុងការសម្របសម្រួល និងការដោះស្រាយទំនាស់ជាចាំបាច់ ។

ឯកឧត្តមបានមានមតិផ្តាំផ្ញើថា លោកគ្រូ អ្នកគ្រូ នឹងត្រូវធ្វើការបណ្តុះបណ្តាលបន្តដល់គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ក្រុង ហើយត្រូវធ្វើយ៉ាងណាពង្រឹងសមត្ថភាពពួកគាត់ក្នុងការដោះស្រាយទំនាស់ និងសម្របសម្រួលក្នុងដំណើរការឃោសនាបោះឆ្នោត ។

សូមបញ្ជាក់ថា នៅថ្ងៃទី ៨-៩ ខែ ឧសភា ឆ្នាំ២០០៨ ខាងមុខនេះ គ.ជ.ប នឹងមានបើកវគ្គបណ្តុះបណ្តាលដល់សិក្ខាកាមដែលជាមន្ត្រីបោះឆ្នោតនៅទូទាំង ២៤ ខេត្ត ក្រុង រួមទាំងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតផងដែរ ។